# កម្មវិធីផ្តល់ជំនួយកសាងបណ្តាញបេសស្តាតឡុងប៊ីឆកណ្តាល
# (Best Start Central Long Beach Network Building Grant Program)

## ការដាក់សំណើគំរោងប្រចាំឆ្នាំ ២០២១

ក្នុងនាមជាយុទ្ធនាការមួយរបស់ First 5 LA កម្មវិធី Best Start កំពុងធ្វើកិច្ចការដើម្បីបង្កើតជាសហគមន៍ដ៏ល្អតាមដែលអាចធ្វើបាន សំរាប់ កុមារ និងក្រុមគ្រួសាររបស់គេ។ កម្មវិធី Best Start រួបរួម មាតាបិតា អង្គការក្នុងសហគមន៍ ស្ថាប័ន និងផ្នែកដ៏ទៃ ដើម្បីពង្រឹងគោលនយោបាយ និងធនធាននានា ក្នុងការគាំទ្រមាតាបិតាឲ្យបានល្អប្រសើរ និងបង្កើតសហគមន៍មួយ ដែលកុមារ និងក្រុមគ្រួសាររបស់គេ អាចរីកចំរើន។ កម្មវិធី Best Start ក៏ផ្តល់ផងដែរនូវ វគ្គបណ្តុះបណ្តាលសមត្ថភាព និងភាពជាអ្នកដឹកនាំ ដើម្បីឲ្យអ្នកទាំងអស់នោះ បានសំរេចគោលដៅរបស់គេ និងធានាឲ្យកុមារមានសុវត្ថិភាព មានសុខភាពល្អ និងត្រៀមខ្លួនជាស្រេចក្នុងការរៀនសូត្រ។

គោលបំណងនៃកម្មវិធីជំនួយនេះគឺដើម្បីពង្រឹងឆន្ទៈ ជាក្រុមនៅក្នុងសហគមន៍ ក្នុងអង្គការ និងក្នុងប្រព័ន្ធនានា ដើម្បីពង្រឹងសុវត្ថិភាព ការអភិវឌ្ឍដ៏ជាសុខភាព និងសុខុមាលភាពរបស់កុមារចាប់ពីក្នុងផ្ទៃដល់អាយុ៥ឆ្នាំ និងក្រុមគ្រួសាររបស់គេ ទូទាំងតំបន់ទី៨នៃកម្មវិធី Best Start នៅទីក្រុងវីលមីងតុន (Wilmington) និង ភាគកណ្តាលនៃទីក្រុងឡុងប៊ិច។ អ្នកអាចមើលព្រំប្រទល់នៃសហគមន៍នោះ តាមរយៈផែនទីនៃគេហទំព័រនេះ https://www.first5la.org/article/best-start-communities-map/ ។

គ្រប់សហគមន៍របស់កម្មវិធី Best Start មានអាទិភាពនានាដែលមាននៅក្នុងរបៀបវារៈនៃការផ្លាស់ប្តូររបស់សហគមន៍ (Community Change Agenda – CCA)។ រាល់សំណើផែនការសុំជំនួយសំរាប់បង្កើត បណ្តាញទំនាក់ទំនង និងការសហការត្រូវស្របនឹងអាទិភាពយ៉ាងហោចណាស់មួយ ក្នុងចំនោមអាទិភាពទាំងពួង។

**<u>អាទិភាពរបស់តំបន់ភាគកណ្តាលនៃទីក្រុងឡុងប៊ិចៈ</u>**

1. កសាងចំណេះដឹងសហគមន៍អំពីការវិវឌ្ឍរបស់កុមារ និងជំនាញបីបាច់ថែរក្សាកុមារ
2. ការពារការធ្វើទុក្ខទោសទៅលើកុមារ និងការធ្វេសប្រហែសចំពោះកុមារ
3. បង្កើនការទទួលបានការមើលថែកុមារប្រកបដោយគុណភាព និងតំលៃសមរម្យ
4. បង្កើនការទទួលបានលំនៅដ្ឋានប្រកបដោយគុណភាព និងតំលៃសមរម្យ និងសុវត្ថិភាពផ្នែកសេដ្ឋកិច្ច

**ប្រវត្តិសង្ខេប**

ដើម្បីស្របទៅនឹងរបៀបវារៈនៃការផ្លាស់ប្តូរក្នុងសហគមន៍ (Community Change Agenda-CCA) កម្មវិធីជំនួយទៅលើការបង្កើតបណ្តាញទំនាក់ទំនងរវាងអង្គការនានានៃ Best Start បានរៀបចំឡើងដើម្បីបង្កើតនូវការតាំងចិត្តចូលរួមជាយូរអង្វែង និងនិរន្តរភាពនៃការងាររបស់ Best Start។

**ជំនួយដែលមាន**
ការស្នើសុំជំនួយចន្លោះពី $10,000 - $25,000 នឹងត្រូវទទួលការពិចារណា។

**ពេលវេលានៃជំនួយ**

- ការដាក់ឲ្យដឹងនូវការស្នើគំរោងផែនការ: **ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២១**
- វគ្គផ្ដល់ព័ត៌មានពីជំនួយ: **ថ្ងៃទី ១ ខែមេសាឆ្នាំ ២០២១ ម៉ោង ៤-៥ ល្ងាច**
- ថ្ងៃផុតកំណត់ទទួលសំណើផែនការ: **ថ្ងៃទី ១២ ខែមេសាឆ្នាំ ២០២១ ម៉ោង ១២ ថ្ងៃត្រង់**
- ថ្ងៃសំរេចជ្រើសរើសយកសំណើផែនការ: **ខែឧសភា ឆ្នាំ ២០២១**
**អ្នកនឹងត្រូវបានជូនដំណឹងតាមរយៈអ៊ីម៉ែល ប្រសិនបើជំនួយរបស់អ្នក ត្រូវបានយល់ព្រម ឬបដិសេធ។**

**លក្ខខណ្ឌ**

- អ្នកដាក់ពាក្យត្រូវមានកម្មវិធីដែលដាក់ដំណើរការក្នុងដែនដីនៃតំបន់ទី ៤ របស់ Best Start
- អ្នកដាក់ពាក្យត្រូវអនុវត្តការងារដោយគ្មានភាពរើសអើងទៅលើ ជាតិសាសន៍ សាសនា ភេទ ភាពសំគាល់ភេទ អាយុ សញ្ជាតិដើម ឬភាពពិការឡើយ។
- មិនអនុញ្ញាតិអោយមានព្រឹត្តិការណ៍ឬកម្មវិធីនានា ដែលមានលក្ខណសាសនា ឬនយោបាយឡើយ។
- រាល់អ្នកទទួលជំនួយតំរូវឲ្យចូលរួមក្នុងដំណើរការនៃការវាយតំលៃប្រព័ន្ធផ្លាស់ប្តូរ របស់អង្គការភាពជាដៃគូរនៃអង្គការមិនរកប្រាក់ចំណូល (The Nonprofit Partnership - TNP)។

**វគ្គផ្ដល់ព័ត៌មានពីជំនួយ**
យើងនឹងមានវគ្គផ្ដល់ព័ត៌មានមួយ នៅក្នុងសហគមន៍នីមួយៗនៃតំបន់ទី៤របស់ Best Start។ អ្នកមិនតំរូវ អោយចូលរួមក្នុងវគ្គផ្ដល់ព័ត៌មាននេះទេ ហើយវានឹងមិនប៉ះពាល់ដល់លទ្ធភាពដែលអ្នកនឹងទទួលជំនួយនោះឡើយ។

**ថ្ងៃទី ១ ខែមេសាម៉ោង ៤-៥ ល្ងាចតាមរយៈប្រព័ន្ធ Zoom**

**ចុះឈ្មោះនៅទីនេះ ដើម្បីទទួលនូវតំណរភ្ជាប់៖ https://forms.gle/LLFWN9Nua2wMLWFZ7**

បន្ថែមពីលើនេះ បើមានសំនួរពីជំនួយនេះ លោកអ្នកអាចផ្ញើអ៊ីម៉ែលទៅ Christina Hall, ប្រធានផ្នែកកម្មវិធី Best Start ឬ David McGill, អ្នកសម្របសម្រួលកម្មវិធី តាមរយ: support@tnpsocal.org.

**លក្ខខណ្ឌនៃការវាយតំលៃសំណើផែនការ**
សំណើផែនការត្រូវបានវាយតំលៃពីសំណាក់គណៈកម្មាធិការត្រួតពិនិត្យ ដែលពួកគេនឹងសំរេចលើវិសាលភាពនៃលក្ខខណ្ឌដូចខាងក្រោម:

- កម្មវិធីដែលដាក់ស្នើសមស្របនឹងគោលបំណងរបស់អង្គការនោះ ហើយនឹងគោលបំណងរបស់កម្មវិធីនៃជំនួយដែលបានរៀបរាប់ខាងលើ
- កម្មវិធីដែលបង្កើតនឹងដោះស្រាយនូវអាទិភាពនានាដែលបានកំណត់របស់ របៀបវារៈនៃការផ្លាស់ប្តូរក្នុងសហគមន៍ (CCA) ដោយប្រសិទ្ធិភាព និងអាចបង្កើតនូវដំណោះស្រាយដ៏មានឥទ្ធិពល និងយ៉ាងឆ្នៃប្រឌិត។

- ស្ថាប័នត្រូវរៀបរាប់យ៉ាងក្បោះក្បាយអំពីអ្វីដែលគេអាចជួយបង្កើនកិច្ចសហការ និងផ្តល់តំលៃបន្ថែមដល់ CCA។
- ឆ្លុះបញ្ចាំងពីបទពិសោធន៍ជាមួយសហគមន៍ដែលអ្នកបានផ្តោតលើ និងការចូលដល់សហគមន៍ដែលអ្នកនឹងបំរើសេវាកម្មជូន។
- គោលដៅច្បាស់លាស់ ទាក់ទាញ អាចវាយតំលៃបាន និងអាចសំរេចបានក្នុងរយៈពេលផ្តល់ជំនួយ។
- ត្រូវមានថវិកាជាក់លាក់ក្នុងការគាំទ្រកម្មវិធីដែលស្នើ ដើម្បីបង្ហាញពីការប្រើប្រាស់ជំនួយអោយបានផលល្អ (ដូចជាការចែករំលែកការប្រើប្រាស់ឧបករណ៍ ការផ្តល់ថវិកាផ្គូផ្គង ឬស្វែងរកការគាំទ្រពីប្រភពផ្សេងៗ)។

សំណើគំរោងត្រូវផ្ញើតាមអ៊ីម៉ែលទៅ support@tnpsocal.org មិនអោយហួសពី **ថ្ងៃទី ១២ ខែមេសាឆ្នាំ ២០២១ ម៉ោង ១២ ថ្ងៃត្រង់** សូមសរសេរ ឈ្មោះកម្មវិធីជំនួយ និងឈ្មោះអង្គការរបស់លោកអ្នក នៅក្នុងប្រធានបទនៃអ៊ីម៉ែលរបស់លោកអ្នក។

## ទំព័រដើមនៃសំណើគំរោង

**ព័ត៌មានរបស់អង្គការ**

| | |
|---|---|
| ឈ្មោះអង្គការ | |
| អាស័យដ្ឋានរបស់អង្គការ | |
| លេខបញ្ជីពន្ធរបស់ អង្គការ (EIN) | |
| ចំនួនថវិកាសរុបរបស់អង្គការសំរាប់ឆ្នាំសារពើពន្ធ ចុងក្រោយ | |
| A. ចំណូល | $ |
| B. ចំណាយ | $ |
| ចំនួនអតិថិជនដែលអង្គការបានបំរើប្រចាំឆ្នាំ | |

**ព័ត៌មានអំពីការស្នើជំនួយ**

| | |
|---|---|
| ឈ្មោះកម្មវិធី | |
| គំរោងថវិការបស់កម្មវិធី | $ |
| ចំនួនដែលស្នើសុំ | $ |
| ចំនួនភាគរយនៃគំរោងថវិកា | % |
| ចំនួនអតិថិជន (មិនរាប់ជាន់គ្នា) ដែលកម្មវិធីបានបំរើរហូតពេញកម្មវិធី | |

**ព័ត៌មានទំនាក់ទំនងសំរាប់សំណើនេះ**

| | |
|---|---|
| ឈ្មោះ | |
| តួនាទី | |
| អ៊ីម៉ែល | |
| ទូរស័ព្ទ | |

សូមបរិយាយពីប្រវត្តិសង្ខេបរបស់អង្គការអ្នក (3-4 ឃ្លា):

សេចក្តីសង្ខេបអំពីគំរោងសំណើ (2-3 ឃ្លា):

**ការរៀបរាប់**

សូមឆ្លើយតបដោយផ្ទាល់ និងសង្ខេបទៅលើសំនួរខាងក្រោម។ លោកអ្នកអាចសំរួលទំហំនៃចំលើយ នីមួយៗ ប៉ុន្តែចំនួនទំព័រចំលើយសរុបមិនគួរលើសពី ៥ទំព័រឡើយ។ ឃ្លាសំនួរ មិនត្រូវបានរាប់ចូលក្នុងចំនួនកំណត់របស់ទំព័រឡើយ។

1. **សូមរៀបរាប់ពីកម្មវិធីដែលដាក់ស្នើ និងតើវាស្របទៅនឹងអាទិភាពរបស់របៀបវារៈនៃការផ្លាស់ប្តូរសហគមន៍យ៉ាងដូចម្តេច។**

2. **សូមរៀបរាប់ពីប្រជាជនដែលនឹងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីដែលបានស្នើនេះ។** សំរាប់ក្រុម អង្គការដែលរួមគ្នា សូមប្រាប់ពីអ្នកដែលចូលរួមពាក់ព័ន្ធ។

3. **សូមរៀបរាប់ពីគោលដៅរបស់កម្មវិធី គោលបំណង និងលទ្ធផលដែលអាចវាយតំលៃបាន។** នៅក្នុងលទ្ធផលដែលអាចវាស់បាន សូមរៀបរាប់ពីប្រភេទនៃសេវាដែលនឹងផ្តល់ គោលដៅប្រជាជនដែលនឹងផ្តល់សេវាដល់ និងចំនួនអតិថិជនដែលនឹងផ្តល់សេវា។ សំរាប់កម្មវិធីដែលកំពុងបន្តដំណើរការ សូមផ្តល់ជាសង្ខេបនូវលទ្ធផល ឬអ្វីដែលបានសម្រេច ពីកម្មវិធីដែលទើបបានបញ្ចប់ ក្នុងឆ្នាំដែលទើបបញ្ចប់ និងឆ្នាំកន្លងមក។

4. **តើអ្នកនឹងប្រើប្រាស់ជំនួយនេះយ៉ាងដូចម្តេច?**

5. **សូមរៀបរាប់ពីការចូលរួមរបស់អង្គការរបស់អ្នកក្នុងភាពជាដៃគូរបស់ Best Start។** ប្រសិនបើលោកអ្នកមានភាពថ្មីស្រឡាងចំពោះការចូលរួមជាដៃគូរ សូមរៀបរាប់ពីចក្ខុវិស័យនៃការចូលរួម និងការធ្វើ សមាហរណកម្ម (ការបញ្ចូលគ្នា) នៅក្នុងភាពជាដៃគូរនេះ។

6. **ចូរពិពណ៌នា អំពីរបៀបដែលអង្គការរបស់អ្នក ចូលរួមជាមួយសមាជិកសហគមន៍។** ឧទាហរណ៍៖ សមាជិកសហគមន៍គឺជាផ្នែកមួយ នៃដំណើរការរៀបចំផែនការ កម្មវិធីរបស់អ្នក, ជាគណៈកម្មការប្រឹក្សាយោបល់ ។ល។

7. **ចូរពិពណ៌នា អំពីរបៀបដែលអង្គការរបស់អ្នក ផ្តល់ឱកាសក្នុងការកសាងសមត្ថភាពដល់សមាជិកសហគមន៍។**

8. **តើអាទិភាពនានានៃការផ្លាស់ប្តូរសហគមន៍របស់យុទ្ធនាការ Best Start ស្របនឹងគោលបំណងរបស់អង្គការលោកអ្នកឬទេ។**

9. **សូមរៀបរាប់ពីគំរោងរយៈពេលវែង ដែលអង្គការលោកអ្នកមានសំរាប់ទ្រទ្រង់កម្មវិធីនេះ។**
សូមរាប់បញ្ចូលរាល់ការផ្តល់ជំនួយដែលបានសំរេចរួច ឬកំពុងរង់ចាំ ទាំងឈ្មោះជំនួយ និងចំនួនទឹកប្រាក់។

10. **សូមរៀបរាប់វិធីសាស្រ្តដែលលោកអ្នកវាយតំលៃភាពជោគជ័យក្នុងការប្រើប្រាស់ជំនួយនេះ។**

**ឯកសាភ្ជាប់:**

សូមផ្តល់ចំនួនកញ្ចប់ថវិកា ឆ្នាំបច្ចុប្បន្ន និងទំរង់បែបបទឯកសា 990 ថ្មីចុងក្រោយ (ប្រសិនបើមាន) ជាមួយឯកសាពាក្យសុំ។